DHCS CALIFORNIA DEPARTMENT OF HEALTH CARE SERVICES

Medi-Cal

XX/XX/XXXX

JOHN SAMPLE
1234 SAMPLE STREET
ANYTOWN CA 90000

ជូនចំពោះសមាជិក Medi-Cal ជាទីគោរព

ក្រោយថ្ងៃទី **1 ខែកក្កដា ឆ្នាំ 2026** Medi-Cal នឹងឈប់គ្របដណ្ដប់លើសេវាកម្មធ្មេញសម្រាប់សមាជិកពេញវ័យមួយចំនួន លើកលែងតែករណីអាសន្ន (ដូចដែលបានយោងខាងក្រោម)។ កាលបរិច្ឆេទចូលជាធរមានសម្រាប់ការផ្លាស់ប្តូរនេះត្រូវបានពន្យារពេលទៅ **ថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2027**។ ការផ្លាស់ប្តូរនេះគឺផ្អែកលើស្ថានភាពអន្តោប្រវេសន៍។ ការផ្លាស់ប្តូរនេះប៉ះពាល់តែសមាជិក Medi-Cal ដែលមានអាយុ 19 ឆ្នាំឡើងទៅប៉ុណ្ណោះ និង មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ Medi-Cal ពេញលេញរបស់សហព័ន្ធ។ សមាជិកដែលរងផលប៉ះពាល់ដោយការផ្លាស់ប្តូរនេះត្រូវបានលើកទឹកចិត្តឱ្យស្វែងរកការថែទាំធ្មេញដែលត្រូវការឥឡូវនេះ - មុន **ថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2027** ។

ដើម្បីស្វែងយល់ថាតើការផ្លាស់ប្តូរនេះអនុវត្តចំពោះអ្នកឬអត់ សូមអានតារាងស្ថានភាពអន្តោប្រវេសន៍នៅ៖ **https://www.dhcs.ca.gov/Medi-Cal/Pages/immigration-status-categories.aspx.**

អ្នកនឹងរក្សាបាននូវអត្ថប្រយោជន៍ Medi-Cal ពេញលេញជាមួយនឹងអត្ថប្រយោជន៍ធ្មេញ ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ ប្រសិនបើ៖

- អ្នកមានផ្ទៃពោះ (និងរហូតដល់មួយឆ្នាំបន្ទាប់ពីការមានផ្ទៃពោះបានបញ្ចប់) ឬ
- អ្នកមានអាយុក្រោម 19 ឆ្នាំ ឬ
- អ្នកមានអាយុក្រោម 26 ឆ្នាំ ហើយស្ថិតនៅក្នុងការថែទាំចិញ្ចឹមនៅថ្ងៃខួបកំណើតគម្រប់ 18 ឆ្នាំរបស់អ្នក។

?

ប្រសិនបើអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ Medi-Cal វិសាលភាពពេញលេញជាមួយនឹងអត្ថប្រយោជន៍ធ្មេញទេ អ្នកអាចទទួលបានសេវាធ្មេញបន្ទាន់។

**តើសេវាថែទាំធ្មេញបន្ទាន់មានអ្វីខ្លះ?**
សេវាថែទាំធ្មេញបន្ទាន់គឺជាការព្យាបាលដែលត្រូវការភ្លាមៗ ដើម្បីបញ្ឈប់ការឈឺចាប់ធ្ងន់ធ្ងរ ឬធ្វើរោគវិនិច្ឆ័យ និងព្យាបាលបញ្ហាវេជ្ជសាស្ត្រភ្លាមៗ និងធ្ងន់ធ្ងរ។ សេវាថែទាំធ្មេញបន្ទាន់អាចធ្វើឡើងសម្រាប់៖

- ការហូរឈាមមិនឈប់
- ការហើមឈឺចាប់នៅក្នុង ឬជុំវិញមាត់របស់អ្នក
- ឈឺធ្មេញឬឈឺថ្គាម។
- របួសដល់មុខឬថ្គាម។
- ការឆ្លងមេរោគនៅក្នុងអញ្ចាញធ្មេញ ឬធ្មេញរបស់អ្នក ជាមួយនឹងការឈឺចាប់ ឬហើម។
- ការថែទាំក្រោយការវះកាត់ (ដូចជាការផ្លាស់ប្តូរបង់រុំ ឬការដកថ្នេរចេញ)។
- ធ្មេញបាក់ ឬ បាក់ចេញ
- ការកាត់ ឬកែតម្រូវខ្សែដែកលើធ្មេញដែលពត់ហើយដែលធ្វើឲ្យថ្ពាល់ ឬអញ្ចាញធ្មេញរបស់អ្នកឈឺចាប់

ដើម្បីស្វែងយល់បន្ថែមអំពីសេវាសង្គ្រោះបន្ទាន់ សូមចូលទៅកាន់៖
**https://smilecalifornia.org/common-questions-2/what-should-i-do-if-i-have-a-dental-emergency/។**

**តើខ្ញុំត្រូវធ្វើអ្វីខ្លះ?**

- ប្រសិនបើការផ្លាស់ប្តូរនេះប៉ះពាល់ដល់អ្នក អ្នកអាចប្រើប្រាស់អត្ថប្រយោជន៍ធ្មេញ Medi-Cal របស់អ្នករហូតដល់ថ្ងៃទី **30 ខែមិថុនា ឆ្នាំ 2027**។ ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2027 តទៅ អ្នកនឹងលែងមានអត្ថប្រយោជន៍ធ្មេញពេញលេញទៀតហើយ ហើយអាចត្រូវបានលុបឈ្មោះចេញពីផែនការថែទាំធ្មេញ Medi-Cal របស់អ្នក (ផែនការថែទាំធ្មេញដែលគ្រប់គ្រង)។
- ប្រសិនបើអ្នកមានអាសន្នផ្នែកធ្មេញ អ្នកអាចទៅជួបអ្នកផ្តល់សេវាធ្មេញ Medi-Cal ដើម្បីទទួលបានការថែទាំ។
- ដើម្បីស្វែងរកពេទ្យធ្មេញ Medi-Cal នៅជិតអ្នក សូមចូលទៅកាន់៖ **https://dental.dhcs.ca.gov/find-a-dentist/home.** ឬទូរស័ព្ទទៅ Medi-Cal Dental តាមរយៈលេខ **1-800-322-6384** ។

- ដើម្បីស្វែងយល់បន្ថែមអំពី Medi-Cal Dental សូមចូលទៅកាន់៖ **https://smilecalifornia.org/.**
- ប្រសិនបើស្ថានភាពអន្តោប្រវេសន៍របស់អ្នកផ្លាស់ប្តូរ សូមទាក់ទងការិយាល័យ Medi-Cal ក្នុងស្រុករបស់អ្នកដើម្បីស្វែងយល់ថាតើអ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់សេវាកម្មធ្មេញឬអត់។ ស្វែងរកព័ត៌មានការិយាល័យ Medi-Cal ក្នុងខោនធីរបស់អ្នកនៅ៖ **dhcs.ca.gov/COL**
- ដើម្បីរាយការណ៍ថាអ្នកមានផ្ទៃពោះ ឬក្នុងរយៈពេល 12 ខែបន្ទាប់ពីការមានផ្ទៃពោះរបស់អ្នកបានបញ្ចប់ សូមទាក់ទងការិយាល័យ Medi-Cal ក្នុងខោនធីរបស់អ្នក។
- អ្នកនឹងរក្សាអត្ថប្រយោជន៍ធ្មេញ Medi-Cal របស់អ្នក ហើយនឹងត្រូវបានផ្លាស់ទីទៅសេវាបង់ថ្លៃធ្មេញ Medi-Cal សម្រាប់អត្ថប្រយោជន៍ធ្មេញពេញលេញរបស់អ្នក ប្រសិនបើអ្នក៖
  - មានផ្ទៃពោះ ឬក្រោយសម្រាលកូនមួយឆ្នាំ (បន្ទាប់ពីមានផ្ទៃពោះ) និង/ឬ
  - កូនចិញ្ចឹម/យុវជនចិញ្ចឹម ឬអតីតយុវជនចិញ្ចឹមដែលមានអាយុក្រោម 26 ឆ្នាំ ដែលធ្លាប់ស្ថិតនៅក្នុងការថែទាំចិញ្ចឹមនៅថ្ងៃខួបកំណើតគម្រប់ 18 ឆ្នាំរបស់អ្នក

**ស្វែងយល់បន្ថែមអំពី Medi-Cal Dental**

សម្រាប់ចម្លើយចំពោះសំណួរអំពីស្ថានភាពអន្តោប្រវេសន៍ណាដែលការផ្លាស់ប្តូរប៉ះពាល់ដល់ សូមអានសំណួរដែលត្រូវបានសួរញឹកញាប់ (FAQ)។

សូមប្រើប្រាស់ស្មាតហ្វូនរបស់អ្នកដើម្បីស្កេនលេខកូដ QR ខាងក្រោម ឬចូលទៅកាន់ **https://www.dhcs.ca.gov/services/Pages/Medi-Cal-Dental-Benefit-Changes-Frequently-Asked-Questions.aspx**

**សម្រាប់ជំនួយបន្ថែម៖**

- សូមទូរស័ព្ទទៅ Medi-Cal Dental ចាប់ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ម៉ោង 8 ព្រឹក ដល់ 5 ល្ងាច (លើកលែងតែ ថ្ងៃឈប់សម្រាករដ្ឋ) តាមរយៈលេខ **1-800-322-6384** ។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។

- សម្រាប់សំណួរអំពីសិទ្ធិទទួលបាន អត្ថប្រយោជន៍ និងសេវាកម្មនានា សូមទូរស័ព្ទទៅកាន់ខ្សែជំនួយ Medi-Cal ចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 5 ល្ងាច (លើកលែងតែថ្ងៃឈប់សម្រាករបស់រដ្ឋ) តាមរយៈ**លេខ 1-800-541-5555** ។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។
- សម្រាប់ជំនួយក្នុងការប្រើប្រាស់អត្ថប្រយោជន៍របស់អ្នក និងការយល់ដឹងអំពីសិទ្ធិរបស់អ្នក សូមផ្ញើអ៊ីមែលទៅ **MMCDOmbudsmanOffice@dhcs.ca.gov.** សូមទូរស័ព្ទទៅកាន់ **1-888-452-8609** (TTY៖ 711 សម្រាប់ការបញ្ជូនតរដ្ឋកាលីហ្វ័រញ៉ា) ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ម៉ោង 8 ព្រឹក ដល់ 5 ល្ងាច លើកលែងតែថ្ងៃឈប់សម្រាករបស់រដ្ឋ។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។ ឬចូលទៅកាន់៖ **https://www.dhcs.ca.gov/services/MH/Pages/mh-ombudsman.aspx.**
- សម្រាប់ជំនួយក្នុងការជ្រើសរើសផែនការសុខភាព និងធ្មេញ សូមទូរស័ព្ទទៅ Medi-Cal Health Care Options (HCO) ចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 6 ល្ងាច តាមរយៈលេខ **1-800-430-4263** (TTY: 1-800-430-7077)។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។ ឬចូលទៅកាន់ Medi-Cal HCO តាមរយៈគេហទំព័រ **www.healthcareoptions.dhcs.ca.gov.**
- សម្រាប់សំណួរអំពីផែនការថែទាំធ្មេញរបស់អ្នក សូមទូរស័ព្ទទៅលេខនៅខាងក្រោយកាតផែនការថែទាំធ្មេញ Medi-Cal របស់អ្នក។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។
- ដើម្បីស្វែងយល់បន្ថែមអំពីការផ្លាស់ប្តូរ Medi-Cal សូមចូលទៅកាន់៖ **https://www.dhcs.ca.gov/Medi-Cal/Pages/changes.aspx.**
- សម្រាប់សំណួរអំពីការផ្លាស់ប្តូរវិសាលភាពនៃការធានារ៉ាប់រង Medi-Cal ដោយផ្អែកលើស្ថានភាពអន្តោប្រវេសន៍ សូមផ្ញើអ៊ីមែលទៅ **ImmigrationPolicy@dhcs.ca.gov.**
- ដើម្បីស្វែងរកការិយាល័យខោនធីក្នុងតំបន់របស់អ្នក សូមចូលទៅកាន់៖ **dhcs.ca.gov/COL**។

អរគុណ

ក្រសួងសេវាសុខាភិបាលរដ្ឋ California